**សាធារណៈរដ្ឋហ្វីលីពីន**

**តុលាការកំពូល**

**រដ្ឋធានីម៉ានីល**

**ផ្នែកទី២ (Second Division)**

**លេខ៖ G.R. L-46373 ថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៨៨**

**ដើមបណ្ដឹងសាទុក្ខ (Petitioner)៖ YAP PENG CHONG**

**ចុងចម្លើយ៖ សាធារណៈរដ្ឋហ្វីលីពីន និងតុលាការឧទ្ធរណ៍**

**YAP, J.:**

គោលបំណងរបស់ញត្តិនេះ គឺដើម្បីស្នើសុំឱ្យមានការពិនិត្យឡើងវិញនូវសេចក្ដីសម្រេច របស់តុលាការឧទ្ធរណ៍ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ១៩៧៧ ដែលគាំទ្រការផ្ដន្ទាទោសចំពោះដើមបណ្ដឹង ពីបទរំលោភបំពាន ច្បាប់លេខ ៣៧២០ (ច្បាប់ស្ដីពីអាហារ ឱសថ និងគ្រឿងសំអាង- **Food, Drug and Cosmetic Act)** និង<u>សេចក្ដីសម្រេច</u>ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ១៩៧៧ បដិសេធនូវញត្តិរបស់ដើមបណ្ដឹង ស្នើនូវការពិចារណាឡើងវិញ ។

ដើមបណ្ដឹង Yap Peng Chong និងអ្នកផ្សេងទៀត មាន Clarita Terragosa,Rolando Lacdao, Mario Uy និង Dario Chamarao ត្រូវបានចោទប្រកាន់ ពីបទរំលោភទៅនឹងមាត្រា ១១ ភ្ជាប់នឹងមាត្រាពាក់ព័ន្ធ ផ្សេងទៀត ដូចជាមាត្រា ១២ មាត្រា ១៨ និង មាត្រា ១៩ នៃ ច្បាប់លេខ ៣៧២០ ដោយបានរួមគំនិតទុច្ចរិត (conspiracy) ក្នុងការផលិត លក់ ចែកចាយ និងដឹកជញ្ជូន ដោយគ្មានការអនុញ្ញាតត្រឹមត្រូវ នូវផលិតផលឱសថ និង/ឬ ថ្នាំគ្រាប់ (tablets) ដែល

ជាផលិតផលក្លែងក្លាយ ឬខូចគុណភាព (adulterated) និងបិទស្លាកសញ្ញាមិនបានត្រឹមត្រូវ (mislabel) ។ នីតិវិធីជំនុំជម្រះក្ដីនៅសាលាដំបូង បានធ្វើឡើងប្រឆាំងនឹងជនជាប់ចោទ Yap Peng Chong, Rolando Lacdao និង Mario Uy ខណៈដែល ជនជាប់ចោទ Clarita Terragosa និង Dario Camrao រត់គេចខ្លួន (remain at large) ។

ក្រោយពេលជំនុំជម្រះក្ដី ដោយសាលាដំបូង នៃទីក្រុង Rizal ជនជាប់ចោទ Mario Uy ត្រូវបានសម្រេចឱ្យរួចខ្លួន ខណៈដែលជនជាប់ចោទ Yap Peng Chong (តទៅ ហៅថា “ដើមបណ្ដឹង”) និង Rolando Lacdao ត្រូវបានចោទប្រកាន់ និងផ្ដន្ទាទោសព្រហ្មទណ្ឌ នៅក្នុងកម្រិតទោសពន្ធនាគារ យ៉ាងតិចពី ៦ ខែ ១ ថ្ងៃ៥ ឆ្នាំយ៉ាងយូរ ព្រមទាំងពិន័យជាប្រាក់ ១,000P ក្នុងម្នាក់ ព្រមទាំងការអនុវត្តទោសពន្ធនាគារបន្ថែម (subsidiary imprisonment) ក្នុងករណីដែលមិនមានលទ្ធភាពបង់ប្រាក់ពិន័យ ក្នុងអត្រាប្រាក់ ៨ P ក្នុងមួយថ្ងៃ ដែលទោះបីជាយ៉ាងនេះក្ដី ការអនុវត្តទោសនេះ មិនត្រូវលើស១/៣ នៃមូលទោស (principal penalty) និងត្រូវបង់ថ្លៃ (តុលាការ) ។

ដើមបណ្ដឹង Yap Peng Chong បានប្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្ដីសម្រេចខាងលើនេះ ទៅកាន់តុលាការឧទ្ធរណ៍ ដែលតុលាការឧទ្ធរណ៍នេះគាំទ្រសេចក្ដីសម្រេចខាងលើ ដោយលើកឡើងដូចខាងក្រោម ៖

លើកលែងតែមានការលុបចោលពាក្យពេចន៍ ពាក់ព័ន្ធនឹងទោស ពន្ធនាគារ ដែលដាក់ដោយសាលាដំបូង សេចក្ដីសម្រេច ដែលជាកម្មវត្ថុនៃការប្ដឹងឧទ្ធរណ៍នេះ ត្រូវទុកជាការបាន ។ ការចំណាយ ជាបន្ទុករបស់ដើមបណ្ដឹង ។

ដើមបណ្ដឹង បានលើកឡើងនូវបញ្ហាពីរ នៅក្នុងបណ្ដឹងនេះ ។ ទីមួយ គឺដើមបណ្ដឹង អះអាងថា សាលាដំបូង ( the court a quo) បានចោទប្រកាន់គាត់ ដោយផ្អែកជាសំខាន់ទៅលើមូលដ្ឋាន នៃការឆ្លើយសារភាព ក្រៅតុលាការ (extrajudicial confession) ដែលការឆ្លើយសារភាពនោះ ជាការរៀបចំឡើង ដោយ ភ្នាក់ងារNBI ដោយមិនមាន ការចូលរួមរបស់គាត់ ហើយគាត់បានចុះហត្ថលេខាលើឯកសារនោះ ដោយមិនបានដឹងពីខ្លឹមសារនៅក្នុងឯកសារនោះឡើយ ព្រោះថា គាត់ត្រូវបានគេធ្វើបាប (maltreated) និង គំរាមកំហែង ជាមួយនឹងការបណ្ដេញចេញទៅប្រទេសចិន ។ ដើមបណ្ដឹង បានអះអាងទៀតថា ការសារភាពក្រៅតុលាការ របស់គាត់ បានធ្វើឡើងដោយមិនស្ម័គ្រចិត្ត ហេតុនេះហើយ វាមិនអាចយកជាភស្តុតាងបានឡើយ ។

ទីពីរ ដើមបណ្ដឹងបានអះអាងថា ភស្តុតាងដែលបានលើកយកមកបង្ហាញ មិនគ្រប់គ្រាន់ ដើម្បីគ្របលើគោលការណ៍សន្មត់ជាមុនថាមិនទាន់មានទោស និង ធ្វើយុត្តិកម្មលើពិរុទ្ធភាពទេ។

បណ្ដឹង របស់ដើមបណ្ដឹង មិនមានមូលដ្ឋានគ្រាន់ឡើយ ។ ដើមបណ្ដឹង មិនបានបង្ហាញភស្តុតាងគ្រប់គ្រាន់ ឱ្យតុលាការជឿជាក់បាន ដើម្បី ច្រានចោលសេចក្ដីសម្រេចរបស់តុលាការឧទ្ធរណ៍បានឡើយ ។

ពាក់ព័ន្ធនឹងការអះអាងរបស់ដើមបណ្ដឹងដែលថា ការសារភាពក្រៅតុលាការ របស់គាត់ ត្រូវបានធ្វើឡើងដោយមិនស្ម័គ្រចិត្ត មិនត្រូវបានតុលាការឧទ្ធរណ៍ជឿជាក់ឡើយ ។ តុលាការបានលើកឡើងថា ៖

ដើមបណ្ដឹង បានតវ៉ាថា ការសារភាពដោយមានការចុះហត្ថលេខារបស់គាត់ ត្រូវបានធ្វើឡើងដោយមិនស្ម័គ្រចិត្ត ដោយសារ "អំពើឃោរឃៅ និងការគំរាមកំហែង" ចំពោះគាត់ ពីសំណាក់ ភ្នាក់ងារ NBI ក្នុងអំឡុងពេលនៃការស៊ើបអង្កេត។ គាត់បាន<u>ចោទថា</u> មុនពេលគាត់ត្រូវបានបញ្ជូនទៅស្នាក់ការកណ្ដាល (headquarter ) នៃNBI ភ្នាក់ងារ បានវាយដំគាត់ ហើយបានដកហូតយកឯកសារអត្តសញ្ញាណ របស់គាត់ទៀតផង ។ គាត់បានបន្ថែមថា គាត់ត្រូវបានបង្ខំឱ្យចុះហត្ថលេខាលើ ភស្តុតាង (Exhibits) "A" "A-1" ដល់ "A-2" ក្រោមការយល់ខុសថា ការធ្វើរបៀបនេះ នឹងគ្រាន់តែបានប្រើប្រាស់ សម្រាប់ជាភស្តុតាង ប្រឆាំងនឹង Dario Camarao ។

គួរកត់សម្គាល់ថា ការសារភាព ត្រូវបានធ្វើឡើងនៅថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ១៩៦៧ ជាកាលបរិច្ឆេទដែល មានការឆែកឆេរ និងចាប់ខ្លួនដើមបណ្ដឹង និងអ្នកដទៃទៀត ។ ហេតុអ្វីបានជា ដើមបណ្ដឹង ក្លាយជាកម្មវត្ថុនៃការធ្វើ អំពើឃោរឃៅ ខណៈដែលគាត់បានចុះហត្ថលេខា លើលិខិតសារភាព នៅថ្ងៃដំបូងរួចទៅហើយនោះ ? ដូចគ្នានេះដែរ ប្រសិនបើដើមបណ្ដឹង ត្រូវបានធ្វើទុក្ខបុកម្នេញ និងទទួលរងអំពើឃោរឃៅ ហេតុអ្វីបានជា នៅពេលគាត់ត្រូវបានជំនុំជម្រះនៅសាលាដំបូង គាត់មិនបានលើកឡើងពីបញ្ហានេះសូម្បីមួយម៉ាត់? មិនតែប៉ុណ្ណោះ ក្រៅពីការចោទប្រកាន់ ដែលថាគាត់ត្រូវបានធ្វើបាប ដើមបណ្ដឹង មិនបានបង្ហាញភស្តុតាងបញ្ជាក់ឡើយ ។ មិនមានភស្តុតាងណាមួយ ត្រូវបានលើកឡើង ដើម្បីបង្ហាញថា ដើមបណ្ដឹង បានត្អូញត្អែរចំពោះមុខមន្ត្រីដែលបានស្បថ ហើយក៏មិន

មានសញ្ញាណាមួយ ដែលនាំឱ្យមានការសង្ស័យ អំពីភាពត្រឹមត្រូវនៃការសារភាពក្រៅតុលាការឡើយ (ទំព័រ ៣៦-៣៧ Rollo) ។

ជាងនេះទៅទៀត តុលាការដែលជាចុងចម្លើយ បានរកឃើញថា ទោះបីជាមិនមានការសារភាពក្រៅតុលាការ នៅតែមានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ដើមបណ្តឹងបាន ដោយហួសពីវិមតិសង្ស័យ (beyond reasonable doubt) ។ តុលាការ បានលើកឡើងថា ៖

ភស្តុតាងនៃការចោទប្រកាន់ បង្ហាញថា នៅព្រឹកថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ១៩៦៧ ភ្នាក់ងារការិយាល័យស៊ើបអង្កេតជាតិ បានចុះឆែកឆេរ នៅផ្ទះលេខ ១៣៥ P. ផ្លូវ Milagros Sna Juan Rizal ដោយមានដីការឆែកឆេរ ដែលចេញដោយចៅក្រម Andres Reyes នៃសាលាដំបូង ទីក្រុង Rizal (ឧបសម្ព័ន្ធ “B”) ។ ភ្នាក់ងារ NBI ដែលដឹកនាំដោយលោក Federico M. Opinion, Jr. បានរឹបអូសយកឱសថជាច្រើនប្រភេទ រួមទាំងស្លាកសញ្ញា កំប៉ុងទទេ អក្សរ ចាន ម៉ាស៊ីនផលិតថ្នាំគ្រាប់ (skin dryers tableting machines) ថ្នាំពណ៌ដែលបានចោះ និងបង្កើតជាពុម្ពរួច (punches and moulds coloring liquid) កោសិកាប្លាស្ទិក (plastic cells) និង ឧបករណ៍ផ្សេងៗទៀត (paraphernalia)។ Yap Peng Chong, Clarita Terragosa និង ម្ចាស់ផ្ទះឈ្មោះ Bartolome Berrame ដែលនៅក្នុងផ្ទះនោះ ត្រូវបានឃាត់ខ្លួន (apprehended)។ អ្នកចុះឆែកឆេរ បានធ្វើបញ្ជីសារពើភណ្ឌ នៃវត្ថុដែលបានរឹបអូស ដែលបញ្ជីនោះត្រូវបានដើមបណ្តឹងទទួលស្គាល់ តាមរយៈហត្ថលេខារបស់គាត់ ។ គេក៏បានថត រូបភាពអ្វីៗនៅជុំវិញនោះ ក៏ដូចជារូបភាពវត្ថុដែលត្រូវបានរឹបអូសផងដែរ ។

ការចុះឆែកឆេរនេះ ធ្វើឡើងក្រោយពេលឃ្លាំមើលជាងមួយខែ ចំពោះផ្ទះនោះ ដោយភ្នាក់ងារ NBI ដោយផ្អែកលើព័ត៌មានថា ផ្ទះដែលដើមបណ្ដឹងឧទ្ធរណ៍កំពុងស្នាក់នៅនោះ ត្រូវបានប្រើប្រាស់ក្នុងការផលិតឱសថក្លែងក្លាយ ។ មុនពេលធ្វើការឆែកឆេរ ភ្នាក់ងារNBI ឈ្មោះ Opinion បានក្លែងខ្លួនជាអ្នកទិញធម្មតាម្នាក់ ហើយបានទិញឱសថនោះពី ដើមបណ្ដឹង ដែលក្នុងនោះមាន ថ្នាំឈ្មោះ Winstral tablets centamin និង carboguanacil ។

ក្រោយការឆែកឆេរ ដើមបណ្ដឹង និងគូកន បានត្រូវបញ្ជូនទៅ ស្នាក់ការកណ្ដាល NBI ហើយត្រូវបានស្ដាប់ចម្លើយ (their statements were taken down) ។ ចម្លើយរបស់ដើមបណ្ដឹង ត្រូវបានធ្វើនៅថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ១៩៦៧ ( ភស្តុតាង A, A-1 ដល់ A-4) ដែលមាន ៤ ទំព័រ ហើយនៅទំព័រចុងក្រោយ ផ្នែកខាងក្រោម ដើមបណ្ដឹង បានចុះហត្ថលេខាដោយសរសេរឈ្មោះរបស់ខ្លួនជាភាសាអង់គ្លេស និងជាអក្សរចិន ព្រមទាំងផ្ដិតមេដៃរបស់ខ្លួនទៀតផង ។

ការពិសោធន៍ ទៅលើឱសថដែលត្រូវបានរឹបអូសនោះ ធ្វើឡើងដោយលោក Arsenio Regala ប្រធានផ្នែកពិសោធន៍ រដ្ឋបាលអាហារ និងឱសថ ។គាត់បានប្រៀបធៀបឱសថនោះ ជាមួយនឹងឱសថ មានអាជ្ញាបណ្ណ និងបានរកឃើញថា ឱសថ ដែលត្រូវបានរឹបអូសនោះ ជាផលិតផលក្លែងក្លាយ ។ ការវិភាគរបស់គាត់បានឱ្យដឹងថា គ្រឿងផ្សំនៃឱសថ ដែលត្រូវបានរឹបអូសនោះ មិនមានស្លាកសញ្ញា និងមិនគោរពតាមការចង្អុលបង្ហាញនៃគ្រឿងផ្សំ ឬរូបមន្ត ដែលកំណត់ដែលច្បាប់លេខ ៣៧២០ នោះឡើយ ។ ដូចគ្នានេះដែរ គាត់បានបង្ហាញក្នុង

របាយការណ៍របស់គាត់ថា ទោះបីជាឱសថដែលបានរឹបអូសនោះ ក្លែងក្លាយក្តី ក៏មិនមានគ្រោះថ្នាក់ដល់សុខភាពដែរ (ទំព័រ ៣៣-៣៤, Rollo)។

យើងបានរកឃើញថា មិនមានហេតុផលអ្វីត្រូវរំខាន ការរកឃើញរបស់តុលាការឧទ្ធរណ៍ទេ។ ហេតុនេះ បណ្តឹង ត្រូវបានបដិសេធ ហើយសេចក្តីសម្រេចរបស់តុលាការឧទ្ធរណ៍ ត្រូវបានទទួលស្គាល់ ។ ការចំណាយ ជាបន្ទុករបស់ ដើមបណ្តឹង ។

សម្រេចដោយ៖ Malencio-Herrera, Paras, Padilla និង Sarmiento, JJ.,

http://www.measboralaws.com/detail/1102